ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ: ១៥០៧សជណ

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែ វិច្ឆិកា ឆ្នាំ ២០១១

ក្រសួងមហាផ្ទៃ
រដ្ឋបាលខេត្ត ឧត្តរមានជ័យ
មកដល់ថ្ងៃទី: ១៥...11...11
ចុះលេខ...ម៉ោង

សម្តេចនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
គោរពជូន
ឯកឧត្តម,ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន

កម្មវត្ថុ : ករណីសំណើសូមគោរពអនុញ្ញាតជាគោលការណ៍ជូនក្រុមហ៊ុន Nature Plantation (K.H) Co., Ltd ធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យដំណាំកសិ-ឧស្សាហកម្ម និងដាំដំណាំកៅស៊ូ លើផ្ទៃដីសរុបចំនួន ៩.០២០ ហិកតា រយៈពេល ៧០ឆ្នាំ ក្នុងដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ភូមិសាស្ត្រខេត្តឧត្តរមានជ័យ ។

យោង : - លិខិតលេខ ១៣៦៦ សណ.ប.ស្ត.អកជ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១១ របស់ក្រសួងបរិស្ថាន
- ចំណាររបស់សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១១ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និង យោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រី សូមជម្រាបជូនឯកឧត្តមមេត្តាជ្រាបថា ចំពោះករណីនេះ រាជរដ្ឋាភិបាលបានយល់ព្រមតាមសំណើរបស់ក្រសួងបរិស្ថាន ដោយអនុញ្ញាតឲ្យក្រុមហ៊ុន Nature Plantation (K.H) Co., Ltd ធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យដំណាំកសិ-ឧស្សាហកម្ម និងដាំដំណាំកៅស៊ូ លើផ្ទៃដីសរុបចំនួន ៩.០២០ ហិកតា (ប្រាំបួនពាន់ ម្ភៃហិកតា) រយៈពេល ៧០ឆ្នាំ ក្នុងដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ភូមិសាស្ត្រខេត្តឧត្តរមានជ័យ ដូចមានផែនទី និងនិយាមកាជូនភ្ជាប់មកជាមួយ ។

ក្នុងកិច្ចដំណើរការវិនិយោគអភិវឌ្ឍន៍នេះ ក្រសួងបរិស្ថានរួមជាមួយអាជ្ញាធរដែនដី និងក្រុមហ៊ុននឹងធ្វើការសិក្សារៀបចំប្លង់មេ កំណត់តំបន់ត្រូវអភិវឌ្ឍន៍ដាំដំណាំកសិ-ឧស្សាហកម្ម ដោយកំណត់មិនឲ្យប៉ះពាល់ដល់ដីលំនៅឋាន ភូមិករ ស្រែចំការស្របច្បាប់របស់ប្រជាពលរដ្ឋ និងត្រូវកំណត់តំបន់នេះ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ស្របតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិ និងអនុវត្តស្របតាមនីតិវិធី នៃច្បាប់ជាធរមាន ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាជ្រាប និង ចាត់ចែងអនុវត្តតាមការគួរ ។

ឧ. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
រដ្ឋលេខាធិការ

ម៉ៅ ឆាវ

ចម្លងជូន
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- សាលាខេត្តឧត្តរមានជ័យ
- រដ្ឋបាលព្រៃឈើ
- ក្រុមហ៊ុន Nature Plantation (K.H) Co., Ltd
- ឯកសារ - កាលប្បវត្តិ

# ផែនទីដីវិនិយោគអភិវឌ្ឍន៍លើវិស័យកសិ-ឧស្សាហកម្ម និងដំណាំកៅស៊ូ របស់ក្រុមហ៊ុន នេតឈ័រ ផ្លេនថេសិន (ខេ.អេច)

NATURE PLANTATION (K.H) CO., LTD ស្ថិតនៅក្នុងដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ភូមិសាស្ត្រស្រុកគ្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ លើផ្ទៃដីចំនួន ៩០២០ ហិកតា




ផែនទី និងនិយាមការនេះ ជាឯកសារ
ភ្ជាប់នឹងលិខិតលេខ ...
ចុះថ្ងៃទី ...... ខែ ...... ឆ្នាំ ២០...
នេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន

ផែនទី និងនិយាមការនេះ ជាឯកសារ
ភ្ជាប់នឹងលិខិតលេខ ...១៤០៤... សជណ
ចុះថ្ងៃទី ...... ខែ ...... ឆ្នាំ ២០...
ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ប៊ូស លាស់

មាត្រដ្ឋាន 1:100,000

0 1 2 Kilometers

Indian_1960_UTM_Zone_48N

សញ្ញាសំគាល់

- ទីតាំងដីវិនិយោគ
- ផ្លូវលំ
- ស្ទឹង, អូរ
- ព្រំប្រទល់ដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព

| ID | N | X | Y |
|---|---|---|---|
| 1 | A | 422785 | 1565357 |
| 2 | B | 428911 | 1565358 |
| 3 | C | 427964 | 1563793 |
| 4 | D | 427780 | 1561926 |
| 5 | E | 427925 | 1561018 |
| 6 | F | 422789 | 1561000 |
| 7 | G | 430851 | 1560041 |
| 8 | H | 430658 | 1562032 |
| 9 | I | 432562 | 1565834 |
| 10 | J | 443607 | 1565834 |
| 11 | K | 446051 | 1564149 |
| 12 | L | 446116 | 1562038 |
| 13 | M | 437959 | 1562053 |
| 14 | N | 437920 | 1560012 |